**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

**សូមគោរពជូន**

**សម្តេចកត្តាព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា**

**សម្តេចកត្តាព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្សឧត្តុង្គឧត្តម នៃពិធីប្រារព្ធខួបកំណើតគម្រប់ ៦៣ ឈានចូល ៦៤ ឆ្នាំ របស់ **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ សូម **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីដឹកនាំកាកបាទក្រហមកម្ពុជាឱ្យទទួលបានជោគជ័យថ្មីៗបន្តទៀត។

យើងខ្ញុំទាំងអស់គ្នាជាកងយោធពលខេមរភូមិន្ទ សូមចូលរួមអបអរសាទរ គាំទ្រយ៉ាងក្លៀវក្លា និងកក់ក្តៅបំផុតចំពោះជោគជ័យនិងសមិទ្ធផលធំៗជាច្រើន ក្នុងបុព្វហេតុបម្រើឧត្តមប្រយោជន៍ជាតិមាតុភូមិ និងប្រជាពលរដ្ឋ ជាពិសេសនៅក្នុងសកម្មភាពមនុស្សធម៌ជួយរំលែកនិងដោះស្រាយរាល់ទុក្ខលំបាករបស់ប្រជាពលរដ្ឋដែលទទួលរងគ្រោះមហន្តរាយផ្សេងៗ **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** តែងតែយកចិត្តទុកដាក់ដោះស្រាយ និងសង្គ្រោះបានទាន់ពេលវេលា ធ្វើឲ្យប្រជាពលរដ្ឋមានជំនឿនិងទំនុកចិត្ត វិស័យមនុស្សធម៌ត្រូវបានលើកស្ទួយកិត្យានុភាព កិត្តិយស និងកិត្តិស័ព្ទ របស់ព្រះរាជាណាចក្រកម្ពុជា កាន់តែខ្ពស់ត្រដែតល្បីរន្ទឺលើឆាកអន្តរជាតិ។

ជាថ្មីម្តងទៀត ក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាមខ្ញុំនិងភរិយា និងកងយោធពលខេមរភូមិន្ទទាំងអស់ សូមលើកហត្ថប្រណម្យបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សាអភិបាលប្រោះព្រំ នូវសព្ទសាធុការពរជ័យគ្រប់យ៉ាងជូន **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ឧត្តមភរិយាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា **បុត្រាបុត្រី** និង**ចៅប្រុស ចៅស្រី**ជាទីស្រលាញ់ ជួបតែសេចក្តីសុខ ជោគជ័យគ្រប់ភារកិច្ច និងប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកត្តាព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែ មិគសិរ ឆ្នាំរកា ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៧ ខែ ធ្នូ គ.ស២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh